Australian Government

Job Services Australia

people • skills • jobs

# Work Experience: Voluntary Work

ការងារស្ម័គ្រចិត្ត (Voluntary Work) អាចជួយឲ្យលោកអ្នកទទួលបានជំនាញនិងបទពិសោធន៍ ទន្ទឹមនឹងការជួយដល់អង្គការសហគមន៍ដែលមិនស្វែងរកប្រាក់ចំណេញ ដែលមានការចុះឈ្មោះត្រឹមត្រូវ។

អ្នកស្វែងរកការងារធ្វើដែលមានអាយុចន្លោះ ពី១៨ទៅ៥៩ឆ្នាំ មានសិទ្ធិចូលរួមក្នុង Voluntary Work។

ការដាក់ឲ្យធ្វើការងារស្ម័គ្រចិត្ត Voluntary Work ត្រូវតែ ៖

- ផ្តល់អត្ថប្រយោជន៍ដល់លោកអ្នកដែលជាអ្នកស្វែងរកការងារធ្វើ និងសហគមន៍ ប៉ុន្តែមិនផ្តល់អត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុដល់អង្គការទទួលឲ្យធ្វើការនោះទេ
- ផ្តល់ជូនលោកអ្នកដែលជាអ្នកស្វែងរកការងារធ្វើនូវឱកាសទទួលបានជំនាញ ដែលនឹងអាចជួយពង្រីកនូវឱកាសរកការងារផ្ទាល់របស់លោកអ្នកនាពេលអនាគត
- ផ្តល់ឱកាសដែលនឹងអភិវឌ្ឍ ឬលើកគុណភាពជំនាញរបស់អ្នកស្វែងរកការងារធ្វើ ក្នុងផ្នែកធ្វើការជាក្រុម ទទួលបានការណែនាំពីអ្នកត្រួតពិនិត្យធ្វើការដោយឯករាជ្យ ចេះប្រាស្រ័យទាក់ទងយ៉ាងប៉ិនប្រសប់ និងជំរុញឲ្យមានទឹកចិត្តថែមទៀតក្នុងការបំពេញការងារ ព្រមទាំងពង្រីកភាពជាម្ចាស់ការលើការងារ។

អង្គការមិនស្វែងរកប្រាក់ចំណេញយ៉ាងច្រើន អាចទទួលលោកអ្នកដែលជាអ្នកស្វែងរកការងារធ្វើឱ្យធ្វើការ Voluntary Work។ អង្គការទាំងនេះរួមមាន ៖

- សេវាស្ម័គ្រចិត្តសង្គ្រោះបន្ទាន់ (ដូចជា សេវាពន្លត់អគ្គិភ័យនៅតាមជនបទ និងសេវាសង្គ្រោះបន្ទាន់តាមរដ្ឋ)
- ក្រុម ឬអង្គការជួយជនងាយរងគ្រោះក្នុងសហគមន៍ ដូចជា ជនចាស់ជរា ឬជនពិការ
- សាលារៀន និងហាងលក់អាហារតាមសាលារៀន
- មណ្ឌលធនធានសម្រាប់ជនអន្តោប្រវេសន៍ (Migrant Resource Centres)
- អង្គការសហគមន៍
- ក្រុមសកម្មភាពសហគមន៍សម្រាប់បរិស្ថាន (ដូចជា Landcare, Waterwatch និងក្រុមការពារប្រភេទសត្វព្រៃកំពុងរងគ្រោះ)
- សេវាសង្គ្រោះសត្វព្រៃ
- ក្រុមកីឡាពុំទាន់មានជំនាញឬទេពកោសល្យ មិនស្វែងរកប្រាក់ចំណេញ
- ឱកាសផ្សេងទៀតដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍។

កំណត់សម្គាល់៖ លោកអ្នកប្រហែលត្រូវឆ្លងកាត់ការឆែកពិនិត្យប្រវត្តិគ្មានឧក្រិដ្ឋកម្មពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសិន មុននឹងធ្វើការជាមួយប្រជាជនតាមកន្លែងថែទាំមនុស្សវ័យជរា ឬធ្វើការជាមួយ ឬនៅជិតកុមារ។

ស្ថាប័នផ្តល់សេវាការងារអូស្ត្រាលី (Job Services Australia) អាចផ្តល់ការណែនាំបាន ថាតើអង្គការណាមានសិទ្ធិផ្តល់ Voluntary Work ដល់លោកអ្នក។

## តើអ្នកណាអាចចូលរួមបាន?

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើ ដែលបានចុះឈ្មោះជាមួយស្ថាប័ន Job Services Australia លោកអ្នកអាចចូលរួមក្នុង Voluntary Work ពេលណាក៏បាន។ ប្រសិនបើលោកអ្នក និងស្ថាប័ន Job Services Australia យល់ស្របថា ការងារនេះនឹងផ្តល់ប្រយោជន៍ដល់លោកអ្នកនោះ ការងារនេះ អាចជាផ្នែកមួយក្នុងផែនការរកការងារ (Employment Pathway Plan) របស់លោកអ្នក។

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើ ដែលត្រូវមានសកម្មភាពបទពិសោធន៍ការងារ (Work Experience Activity Requirement) លោកអ្នកអាចបំពេញតាមតម្រូវការបែបនេះបាន ដោយការចូលរួមជាមួយនឹងការងារស្ម័គ្រចិត្ត។

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើដែលត្រូវបំពេញសកម្មភាពខ្លាំងក្លា (Intensive Activity) លោកអ្នកអាចបំពេញតាមតម្រូវការនេះបានតាមរយៈការចូលរួមជាមួយ Voluntary Work។ ស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នកនឹងផ្តល់ការណែនាំដល់លោកអ្នក ថាតើលោកអ្នកត្រូវបំពេញ Intensive Activity ឬយ៉ាងណា។

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើដែលគ្មានបំណងធ្វើ Voluntary Work ទេ លោកអ្នកគួរត្រូវគេចាត់ ឱ្យចូលរួមក្នុងសកម្មភាព Work Experience ណាមួយទៀតដែលសមស្រប ដើម្បីបំពេញ Work Experience Activity Requirement របស់លោកអ្នក។

## របៀបដាក់ពាក្យសុំ

ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុង Voluntary Work លោកអ្នកគួរទាក់ទងទៅស្ថាប័ន Job Services Australia របស់លោកអ្នក ដើម្បីស្វែងយល់នូវព័ត៌មានបន្ថែម។

## ភាតព្វកិច្ចរបស់លោកអ្នក

ប្រសិនបើលោកអ្នកទទួល Newstart , ប្រាក់ឧបត្ថម្ភយុវជន (Youth Allowance) ឬប្រាក់ជំនួយសម្រាប់ចិញ្ចឹមកូន (Parenting Payment) ដោយមានការតម្រូវឲ្យចូលរួម លោកអ្នកនឹងត្រូវស្វែងរកការងារ ហើយចូលរួមក្នុងសកម្មភាព ដែលនឹងជួយឱ្យលោកអ្នកបានទទួលការងារធ្វើ។

ស្ថាប័នផ្តល់ Job Services Australia នឹងពិចារណាអំពីស្ថានភាពរបស់លោកអ្នកផ្ទាល់ ហើយចរចាអំពីសកម្មភាពសមរម្យ ដើម្បីដាក់បញ្ចូលក្នុងផែនការរកការងារធ្វើ (Employment Pathway Plan) របស់លោកអ្នក។

ប្រសិនបើលោកអ្នកមិនអាចចូលរួមក្នុងសកម្មភាពទាំងនេះបានទេ លោកអ្នកគួរពិភាក្សាជាមួយស្ថាប័នផ្តល់សេវារបស់លោកអ្នក។ ប្រសិនបើលោកអ្នកខកខានមិនបានអនុវត្តសកម្មភាពដែលបានព្រមព្រៀងនោះ ការខកខាននេះអាចប៉ះពាល់ដល់ប្រាក់ជំនួយទ្រទ្រង់ប្រាក់ចំណូលរបស់លោកអ្នក។

10FS09446JSA/khmer

# សិទ្ធិឯកជនរបស់លោកអ្នក

ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ត្រូវបានការពារដោយ *ច្បាប់ឯកជនឆ្នាំ១៩៨៨ (Privacy Act 1988)* ហើយព័ត៌មានអំពីលោកអ្នក អាចត្រូវបានការពារផងដែរដោយ *ច្បាប់ (រដ្ឋបាល) សន្តិសុខសង្គមឆ្នាំ១៩៩៩ (Social Security [Administration] Act 1999)* (ឧទាហរណ៍ ប្រសិនបើលោកអ្នកទទួលប្រាក់ជំនួយទ្រទ្រង់ប្រាក់ចំណូល)។ ព័ត៌មានរបស់លោកអ្នកអាចត្រូវស្ថាប័នផ្តល់ Job Services Australia ព្រមទាំងក្រសួងអប់រំការងារ និងទំនាក់ទំនងកន្លែងធ្វើការ [DEEWR], (Department of Education, Employment and Workplace Relations [DEEWR]) ប្រើប្រាស់រួមគ្នាជាមួយ Centrelink និងក្រសួង ក៏ដូចជាទីភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីផ្សេងៗទៀត ដើម្បីផ្តល់លទ្ធភាពឱ្យអង្គការទាំងនោះ ផ្តល់ជូនលោកអ្នកនូវសេវាដ៏សមស្របបំផុត ដើម្បីបំពេញតាមតម្រូវការរបស់លោកអ្នក។

ចំពោះព័ត៌មានបន្ថែមអំពីភាពឯកជនរបស់លោកអ្នក សូមសាកសួរស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នក DEEWR ឬបើកមើលវ៉ិបសាយថ៍ **privacy.gov.au** ។

# ការធានាផ្តល់ សេវារបស់យើងជូនលោកអ្នក

## ការធានាសេវា

លោកអ្នកនឹងទទួលបានសេវាការងាររៀបចំឡើងសម្រាប់រូបលោកអ្នកផ្ទាល់ដែលផ្តល់ដោយស្ថាប័នផ្តល់ Job Services Australia ។ សេវាទាំងនេះនឹងមានលក្ខណៈបត់បែនទៅតាមស្ថានភាព និងប្រវត្តិការងាររបស់លោកអ្នក។ ដើម្បីមើលពីការធានារបស់សេវាទាំងអស់នេះ សូមចូលទៅវ៉ិបសាយថ៍ **deewr.gov.au/jobservicesaustralia** ។

## ក្រមសីលធម៌វិជ្ជាជីវៈ

ស្ថាប័នផ្តល់ Job Services Australia ចុះកិច្ចសន្យាដើម្បីផ្តល់សេវាការងារដែលឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី និងបានយល់ព្រម ហើយប្តេជ្ញាប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈ ក្នុងការផ្តល់សេវាការងារនេះ។ ដើម្បីមើលក្រមសីលធម៌វិជ្ជាជីវៈ សូមចូលទៅវ៉ិបសាយថ៍ **deewr.gov.au/jobservicesaustralia**។

# សម្រាប់ព័ត៌មានបន្ថែម

**សូមទូរស័ព្ទទៅលេខ 13 17 64 ឬបើកមើលវ៉ិបសាយថ៍ deewr.gov.au/jobservicesaustralia ។**